**អ្នកម្ដាយជាទីគោរព**

នាងខ្ញុំសូមជូនដំណឹងដល់អ្នកម្ដាយអំពីកិច្ចសហប្រតិបត្តិការ នៃការសិក្សានេះ។ នាងខ្ញុំនឹងធ្វើការសិក្សានៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក។ ព័ត៌មានលម្អិតនៃសំណើសុំកិច្ចសហប្រតិបត្តិការនឹងត្រូវបានពិពណ៌នានៅលើផ្ទាំងរូបភាព ដែលនឹងត្រូវបានបិទនៅមន្ទីរពេទ្យ ហើយព័ត៌មាននៃការសិក្សានឹងត្រូវបានបង្ហោះនៅលើគេហទំព័រនៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក។

ខ្ញុំសូមកោតសរសើរចំពោះកិច្ចសហប្រតិបត្តិការរបស់អ្នក។

## ស្នើសុំកិច្ចសហប្រតិបត្តិការ

**ប្រធានបទ៖** ទំនាក់ទំនងរវាងការលើសទម្ងន់ និងការជាត់ក្នុងពេលចាប់ផ្តើមមានផ្ទៃពោះ និងផលវិបាករបស់ម្ដាយនៅកម្ពុជា។

**គោលបំណង៖** ដើម្បីស្វែងយល់អំពីសន្ទស្សន៍ម៉ាសរាងកាយ និងវាយតម្លៃទំនាក់ទំនងរវាងការលើសទម្ងន់ ការជាត់ក្នុងពេលចាប់ផ្តើមមានផ្ទៃពោះ និងផលវិបាករបស់ម្ដាយ។

### តើអ្នកណានឹងត្រូវបានជ្រើសរើសសម្រាប់ការសិក្សានេះ?

ស្ត្រីមានផ្ទៃពោះដែលបានទទួលការថែទាំផ្ទៃពោះនៅមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារកក្នុងអំឡុងពេល ១២ សប្តាហ៍នៃអាយុគភ៌ និងបានសម្រាលនៅចន្លោះខែកុម្ភៈ ឆ្នាំ២០២៣ ដល់ខែមករា ឆ្នាំ២០២៤។ ស្ត្រីមានផ្ទៃពោះចំនួន 400នាក់ នឹងត្រូវបានជ្រើសរើសដោយការយកគំរូតាមកុំព្យូទ័រ។

### ព័ត៌មានលម្អិតនៃកិច្ចសហប្រតិបត្តិការរបស់អ្នកនៅក្នុងការសិក្សានេះ

- យើងនឹងប្រើប្រាស់ព័ត៌មានរបស់អ្នកពីកំណត់ត្រាវេជ្ជសាស្ត្រ ព័ត៌មាននឹងមិនត្រូវបានកំណត់អត្តសញ្ញាណ។
- ប្រសិនបើអ្នកចង់សួរសំណួរសម្រាប់ការបំភ្លឺពីការសិក្សា អ្នកអាចទាក់ទងអ្នកស្រាវជ្រាវតាមអ៊ីមែល ឬទូរស័ព្ទ។
- ប្រសិនបើអ្នកមិនយល់ព្រម ឬមិនអនុញ្ញាតឱ្យយើងប្រើប្រាស់ព័ត៌មាន អ្នកអាចដកខ្លួនចេញពីការសិក្សានេះដោយទាក់ទងអ្នកស្រាវជ្រាវតាមអ៊ីមែល ឬទូរស័ព្ទចាប់ពីចុងខែមករា ឆ្នាំ២០២៤ ដល់ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ យើងនឹងលុបព័ត៌មានរបស់អ្នកចេញពីការសិក្សានេះ។ ប្រសិនបើអ្នកចង់ដកខ្លួនចេញពីការសិក្សាក្រោយការប្រមូលទិន្នន័យថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៤ ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកនឹងមានលក្ខណៈអនាមិក។
- នៅពេលដែលអ្នកមិនយល់ស្រប ឬដកខ្លួនចេញពីការសិក្សានេះ អ្នកនៅតែអាចទទួលបានការថែទាំសុខភាពដែលបានផ្តល់ដូចបច្ចុប្បន្ន និងអនាគតពីមន្ទីរពេទ្យ។
- ទិន្នន័យនឹងមានលក្ខណៈអនាមិក ហើយនឹងបង្ហាញជារួមនៅពេលដែលព័ត៌មានត្រូវបានបោះពុម្ពនៅក្នុងទិនានុប្បវត្តិសិក្សា ឬបង្ហាញក្នុងសន្និសីទ យើងនឹងបង្ហាញលទ្ធផលជូនអ្នកប្រសិនបើអ្នកចង់ដឹងដោយទាក់ទងអ្នកស្រាវជ្រាវ។

### ព័ត៌មានលម្អិតទំនាក់ទំនងអ្នកស្រាវជ្រាវ៖

ឈិន សុខណាយ មន្ត្រីផ្នែកបណ្តុះបណ្តាលនៃមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក
និស្សិតអនុបណ្ឌិតនៅសាកលវិទ្យាល័យ Juntendo ប្រទេសជប៉ុន
ទូរស័ព្ទ៖
012 622 098 (កម្ពុជា) អាចទំនាក់ទំនងបានចាប់ពី 2024/02/22 to 2024/03/19
(+81) 80 7826 0260 (ជប៉ុន) អាចទំនាក់ទំនងបានចាប់ពី 2024/01/22 to 2024/02/20
អ៊ីម៉ែល៖ m3122032@juntendo.ac.jp

**សូមធ្វើការទំនាក់ទំនងអ្នកស្រាវជ្រាវដោយសេរីសម្រាប់សំណួរពីការសិក្សាស្រាវជ្រាវនេះ**